**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥១-០១៥-០៥៤ ធសស

# លិខិតជូនពរ និងអបអរសាទរ

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ធនាគារជាតិនៃកម្ពុជា

**សូមគោរពជូន**
**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេច ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!**

តាងនាមថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ខ្ញុំសូមសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លាកក់ក្តៅបំផុត ប្រកបដោយមនោសញ្ចេតនារំភើបរីករាយក្រៃលែងជូនចំពោះសម្តេច ដែលត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទានគោរមងារជា **សម្តេចក្រឡាហោម ស ខេង** កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៥ ។

សម្តេច គឺជាអ្នកដឹកនាំដ៏ឆ្នើម បានចូលរួមដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កសាងបាននូវសន្តិភាពជាតិ ស្ថិរភាពជាតិ ឯកភាពជាតិ ការអភិវឌ្ឍជាតិលើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ និងមានស្ថិរភាពសន្តិសុខសង្គមល្អប្រសើរ ព្រមទាំងរក្សានិងការពារបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តម ប្រកបដោយនក្ខត្តឫក្សនេះ ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រៃ ទេវតា និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមតាមជួយថែរក្សា ការពារ និងប្រសិទ្ធពរជ័យ បវរសួស្តីមហាប្រសើរ ជូនពរចំពោះ សម្តេច និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ សូមបានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម សម្តេចក្រឡាហោម ស ខេង មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំទាំងអស់គ្នា ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥
**តំណាងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា**
**ទេសាភិបាល**

**ជា-ចាន់តូ**